ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ..៣២០......ប្រក.កសក

# ប្រកាស
# ស្តីពី
# ការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh. Cambodia Phone : (023) 726 128 726 129 Fax : (855) 23 217 320

# សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាព តាមលក្ខណៈសហគមន៍ព្រៃឈើដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់រដ្ឋបាលព្រៃឈើមេមត់ ផ្នែករដ្ឋបាលព្រៃឈើមេមត់នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះនិងអភិវឌ្ឍព្រៃសហគមន៍ឲ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាននិងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម នៃប្រកាសនេះមាន មួយ(១)សហគមន៍ព្រៃឈើដែលមានផ្ទៃដីមួយកន្លែងសរុបចំនួន៦១(សែសិបមួយ)ហិកតា ដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និងជាប្រព័ន្ធខ្សែព្រំបិទជិតកំណត់ដោយចំណុចគោលនិងនិយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើនិងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី...២៩...ខែ...ឧសភា...ឆ្នាំ...២០១២

**រដ្ឋមន្ត្រី**

**ច័ន្ទ សារុន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពង់ចាម
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ១ : ប្រកាសលេខ...៣២១......... ប្រក.កសក ចុះថ្ងៃទី......២១...... ខែ..ឧសភា....... ឆ្នាំ...២០១២

# ទីតាំងព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម




Phum Ro Bong Chrous Community Forest Map in Chom KroVian Commune Maymut District Kampong Cham Province
៨១ ហិកតា
A (639621 1305072)
B (640051 1304789)
C (639698 1304344)
D (639203 1304920)
639740 1305180
639868 1305196
639868 1305122
639921 1305060
640000 1305016
640055 1304968
640088 1304873
640088 1304826
640010 1304717
639974 1304645
639899 1304548
639786 1304337
639660 1304382
639535 1304576
639364 1304567
639274 1304670
639253 1304784
639219 1304971
639392 1305014
639472 1305004
639566 1304990
639633 1304954
639752 1304934
639779 1305051
Coordinate Systems
Projection: UTM
Map Datum: Indian 1960
1:5,500
0 200
Meters

សហគមន៍ភូមិរបេងច្រុះ

| No | X- | Y |
|---|---|---|
| 1 | 639868- | 1305196 |
| 2 | 639868- | 1305122 |
| 3 | 639921- | 1305060 |
| 4 | 640000- | 1305016 |
| 5 | 640055- | 1304968 |
| 6 | 640088- | 1304873 |
| 7 | 640088- | 1304826 |
| 8 | 640051- | 1304789 |
| 9 | 640010- | 1304717 |
| 10 | 639974- | 1304645 |
| 11 | 639899- | 1304548 |
| 12 | 639766- | 1304337 |
| 13 | 639698- | 1304344 |
| 14 | 639660- | 1304382 |
| 15 | 639535- | 1304576 |
| 16 | 639364- | 1304567 |
| 17 | 639274- | 1304670 |
| 18 | 639253- | 1304784 |
| 19 | 639203- | 1304920 |
| 20 | 639219- | 1304971 |
| 21 | 639392- | 1305014 |
| 22 | 639472- | 1305004 |
| 23 | 639566- | 1304990 |
| 24 | 639621- | 1305072 |
| 25 | 639633- | 1304954 |
| 26 | 639752- | 1304934 |
| 27 | 639779- | 1305051 |
| 28 | 639740- | 1305180 |
| 29 | 639868- | 1305196 |

**ឧបសម្ព័ន្ធ ២** ៖ភ្ជាប់ប្រកាសលេខ ...៣២០...... ចុះថ្ងៃទី ២១......ខែ ឧសភា......ឆ្នាំ ២០១២....

# ទីតាំងព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម

| ល.រ | ឈ្មោះសហគមន៍ព្រៃឈើ | ផ្ទៃដី (ហិកតា) | ចំណុចនិយាមការ ទីតាំងព្រៃសហគមន៍ | | | | ចំនួនភូមិ | ឈ្មោះឃុំ | ឈ្មោះស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ភូមិរបង់ច្រុះ | ៤១ | 639868- 1305196<br>639868- 1305122<br>639921- 1305060<br>640000- 1305016<br>640055- 1304968<br>640088- 1304873<br>640088- 1304826 | 640051- 1304789<br>640010- 1304717<br>639974- 1304645<br>639899- 1304548<br>639766- 1304337<br>639698- 1304344<br>639660- 1304382 | 639535- 1304576<br>639364- 1304567<br>639274- 1304670<br>639253- 1304784<br>639203- 1304920<br>639219- 1304971<br>639392- 1305014 | 639472- 1305004<br>639566- 1304990<br>639621- 1305072<br>639633- 1304954<br>639752- 1304934<br>639779- 1305051<br>639740- 1305180<br>639868- 1305196 | ១ | ជាំក្រវៀន | មេមត់ | មេមត់ |
| សរុប | | ៤១ | | | | | ០១ | ០១ | ០១ | ០១ |